
ទស្សនាវដ្ដី
លេខ ៣
ពុទ្ធិកវិទ្យាល័យ
ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦
ភ្នំពេញ

Don Offert par M. Imprimerie VIRIYA PPenh

P-K-13
1956-3

# មាតិការឿង


បណ្ណាធិការ . . . . . . វិចារណកថា ទំព័រទី ១

បណ្ឌិត សម-សុខុម . . . ពុទ្ធទស្សនៈ (ត) „ ៥

. . . . . . ដំណើរសាសនា „ ៨

មហា មាស-ចន . . . . . ប្រវត្តិសង្ខេបនៃនាលន្ទា „ ១២

លោក កែវ-ហាន់ . . . . ពុទ្ធប្បវត្តិ „ ១៥

មហា ថោង-ទិត . . . . ស្ថានការណ៍នៅសហភាពភូមា „ ១៨

ភិក្ខុ អាំ-សួន (ហៅហម) . . លិខិតសមណនិស្សិតយើង „ ២០

. . . . . . សុន្ទរកថា „ ២៤

. . . . . . ប្រអប់លិខិត „ ២៧

. . . . . . សេចក្តីកត់ហេតុមហាសន្និបាត „ ២៩

លោក ប៉ាយ-ប៊ុក . . . . រឿងតុក្កតាធ្វើពីទធិជាតិ (ត) „ ៣០

លោក តែ-ជុន . . . . . ជ័យប្រាជ្ញ (ត) „ ៣២

លោក សួន-ស៊ិន្ទ . . . . បុណ្ណកុមារ (ត) „ ៣៣

. . . . . . ប្រវត្តិក្មេងកំព្រា „ ៣៥


## ដំឡៃឡជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ ខែ | ១ ឆ្នាំ | ១ ក្បាល | ៦ ខែ | ១ ឆ្នាំ | ១ ក្បាល |
| ៥០៛០០ | ១០០៛០០ | ១០៛០០ | ៦០៛០០ | ១២០៛០០ | ១៣៛០០ |

## អ្នកទទួលឡជាវ

សូមផ្ញើចំពោះទៅលោក ម៉ៅ-មុី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

ADRESSE: Monsieur Mao-Mey Ministère de L'Intérieur P.Penh

# វិចារណកថា

## ព្រះរាជាភិសេក

ចាប់តាំងពីថ្ងៃទី២មិនាមក រាជធានីភ្នំពេញមានបរិយាកាសអ៊ូអរទឹកកុះករគ្រប់កន្លែង, នៅតាមវិថីនានានិងមុខគេហស្ថានទាំងឡាយ គេឃើញទង់ជាតិកំពុងតែលំហែខ្លួន រលាស់រំហើរតាមកម្លាំងខ្យល់ រំលេចពណ៌បញ្ចេញលំអរញញឹមពព្រាយរកធម្មជាតិទាំងឡាយគ្រប់ទិសដំបន់ ៗ រុក្ខជាតិទាំងឡាយក៏ព្រួតលាស់ចេញស្លឹកខ្ចីនិងផ្កាផ្លែយ៉ាងខៀវបំព្រង ដែលជាហេតុមួយបណ្តាលឲ្យឃើញថា ជាការថ្វាយពរជ័យចំពោះព្រះមហាក្សត្រប្រទេសកម្ពុជាយើង ដែលរាជរដ្ឋាភិបាលបានរៀបចំធ្វើពិធីព្រះរាជាភិសេកចំពោះព្រះមហាក្សត្រគ្រប់គ្រងព្រះរាជអាណាចក្រកម្ពុជា ៗ

ពិធីដ៏ឧឡារិកបែបនេះយើងមិនសូវធ្លាប់ជួបប្រទះទេ ព្រោះជាពិធីដែលមានតែម្តងក្នុងរជ្ជកាលនៃព្រះមហាក្សត្រមួយព្រះអង្គប៉ុណ្ណោះ ៗ ថ្ងៃទី២មិនា រហូតមកដល់ទី៨មិនា ឆ្នាំ១៩៥៦ គេចាត់ទុកជាថ្ងៃមង្គលមួយយ៉ាងវិសេសក្នុងរជ្ជកាលព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រិត នឹងព្រះមហាក្សត្រិយានី ៗ ប្រជាជនទាំងឡាយក្នុងព្រះរាជអាណាចក្រទាំងមូលបានលះបង់ករណីយផ្ទាល់ខ្លួនគ្រប់គ្នា ដើម្បីមករួមក្នុងព្រះរាជពិធីដ៏ឧឡារិកនេះ, មិនតែប៉ុណ្ណោះ សូម្បីប្រទេសទាំងឡាយមានចំនួនជាង៤០ ដែលបានទទួលស្គាល់ប្រទេសយើងតាមផ្លូវការហើយ ក៏បានចាត់ដំណាងរៀងខ្លួនមករួមក្នុងពិធីនេះដែរ ៗ ខ្ញុំជឿជាក់ថាសតវត្សទី២៥នៃព. ស. គឺជាសតវត្សនាំមកនូវជោគជ័យនិងថ្ងៃថ្នូរដល់កម្ពុជរ

នេះ; ព្រោះថាតាំងពីគ.ស. ១៩៥៤ មកដល់សព្វថ្ងៃ ប្រទេសកម្ពុជាយើងបានយល់ច្បាស់នូវឯករាជរបស់ខ្លួនដោយពេញបរិបូណ៌ ហើយថែមទាំងបានអនុវត្តផែនការរបស់ប្រទេសឲ្យតាំងស៊ប់ក្នុងឋានៈជាអព្យាក្រឹតភាព ក្រោមការដឹកនាំផ្ទាល់នៃសម្តេចព្រះឧបយុវរាជនាយករដ្ឋមន្ត្រីនិងជាអតីតនៃព្រះមហាក្សត្រយើង ។ យើងធ្លាប់ដឹងមកហើយថាការពុះពារដើម្បីប្រទេសជាអព្យាក្រឹត្យ នេះក៏មិនមែនជាកិច្ចដែលធ្វើទៅបានដោយងាយ ៗ នោះទេ គឺត្រូវជួបប្រទះនូវការរាំងរាននឹងបំភាន់បំភ័យគ្រប់ទិសទីជុំវិញខ្លួន, តែថាការនេះនឹងអនុវត្តទៅបានដោយស្រួលហើយងាយផងនោះ លុះណាតែពលរដ្ឋទាំងមូលស្គាល់ការថ្លៃថ្នូរនិងការអត់ធ្មត់មិនមានការយល់ផ្ទុយ ដែលជាហេតុនាំឲ្យអន្តរាយដល់ករណីយរបស់ប្រទេស ។

រដ្ឋកាលនេះជារដ្ឋកាលនាំមកនូវសុវត្ថិភាព, ជោគជ័យនិងជ័យជំនះ; យើងចាំបានទេថា ជាច្រើនសតវត្សមកហើយដែលប្រជាជាតិយើងស្រេកឃ្លាននូវជ័យជំនះបែបនេះជាយូរណាស់មកហើយ, ក្នុងពេលដែលយើងកំពុងស្រេកឃ្លាន ហើយយើងពុំបានសម្រេចដូចបំណងនោះ ក៏ជាហេតុធ្វើឲ្យអាប់ឱនដល់រស្មីនៃមុខរាជយើងដែរ, តែមិនយូរប៉ុន្មានទេបំណងនឹងការប្រឹងប្រែងរបស់យើង ដែលមានព្រះមហាក្សត្រព្រះមហាក្សត្រិយានីនិងសម្តេចឧបយុវរាជជាប្រមុខនោះ ក៏បានយល់ច្បាស់នូវជ័យជំនះដ៏ថ្លៃថ្នូរនេះ ដែលជាហេតុធ្វើឲ្យមុខរាជសម្រាប់ប្រទេសយើង មានពន្លឺរស្មីភ្លឺចាំងច្បាស់ចិញ្ចែងចិញ្ចាចស្មើប្រទេសនានាក្នុងផ្ទៃនៃពិភពលោក ។

ហេតុដែលគួរឲ្យយើងចាំកុំភ្លេច គឺការថ្លៃថ្នូរនិងជ័យជំនះនេះឯង ដែលយើងត្រូវតែរក្សាដោយពួតដៃគ្នាតាមរាជរដ្ឋាភិបាលមានសម្តេចព្រះឧបយុវរាជជាប្រមុខ ។

ក្នុងរយៈកាលមួយសប្ដាហ៍ ដែលរាជធានីភ្នំពេញកំពុងតាំងនៅក្នុងពិធីព្រះរាជាភិសេកយ៉ាងឧឡារិក ដោយមានការស្រែកថ្វាយពរជ័យគ្រប់ទាំងដប់ទិស ទាំងថ្ងៃទាំងយប់ នៅតាមវិទ្យុក៏គេឮសំឡេងថ្វាយព្រះពរគ្រប់ពេលវេលាពុំដែលខាន ៗ ចាប់តាំងពីថ្ងៃទី២មកទល់នឹងថ្ងៃទី៨នេះគេសំគាល់ឃើញថ្ងៃទី៦មិនា ជាថ្ងៃដែលមានបរិយាកាសប្លែកជាងធម្មតា គឺនៅតាមវិថីទាំងឡាយ៤កន្លែងដូចខាងក្រោមៈ វិថីព្រះបាទពញាយ៉ាត, គិរីវិថីព្រះបាទស៊ីសុវត្ថិ, វិថីឧកញ៉ាឈុន, មហាវិថីព្រះបាទនរោត្ដម, វុក្ខវិថីព្រះមហាក្សត្រិយានីកុសុមៈ, មានប្រជាជនទាំងស្រី-ប្រុសចាស់ក្មេងគ្រប់សញ្ជាតិ ចាកនិទ្រាពីព្រលឹមរៀងខ្លួនមកឈរកកកុញមីរដេរដាស ដើម្បីនឹងចាំថ្វាយសព្ទសាធុការចំពោះព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនឹងព្រះមហាក្សត្រិយានីដែលទ្រង់យាងជាក្បួនប្រទក្សិណព្រះរាជធានី ដោយទ្រង់ប្រដាប់ព្រះកាយគ្រប់អាភរណៈទាំងអស់ មានទ្រង់មកុដរាជលើព្រះកេសជាដើម ៗ សំឡេងប្រជាជនរាប់លាននាក់ បានថ្វាយពរសព្ទសាធុការគ្រប់ទិសទីក្នុងព្រះរាជធានីភ្នំពេញ; ការដែលប្រទក្សិណនៃព្រះមហាក្សត្រនឹងព្រះមហាក្សត្រិយានីក្នុងវដ្ដកាលនេះ គួរចាត់ទុកជាពិធីប្រសើរ ហើយថ្លៃថ្លាជាងវដ្ដកាលដែលកន្លងមកហើយមុននេះជាងមួយសតវត្ស; ព្រោះថាសម័យនេះជាសម័យដែលប្រទេសមានអធិបតេយ្យភាព នឹងឯករាជ្យដោយពេញលក្ខណៈ ថែមទាំងតាំងស៊ប់នៅក្នុងអព្យាក្រឹតភាពផង ៗ

បន្ទាប់ពីថ្ងៃទី៦នេះនៅព្រឹកថ្ងៃទី៧ខែដដែល ក៏មានរៀបចំធ្វើពិធីការុញគ្រាសយ៉ាងអធិកអធមក្រៃលែងទៀតដែលមានទាំងកងជីវពលមករួមជាមួយផង នៅវេលាម៉ោង៧, ១៥ នាទី ៗ

ការរៀបរាប់ពីរឿងព្រះរាជាភិសេក ក៏មិត្តអ្នកអានបានជួបប្រទះលើទំព័រសារពត៌

មានជាច្រើនណាស់មកហើយ ខ្ញុំក៏សូមស្មេះមិននាំមកអធិប្បាយជូនតទៅទៀតទេ ជាហេតុនាំឲ្យសាំគំនិតដល់ការអាន, តែដែលយើងតែងផ្ទៀតនាំរឿងនេះមកអធិប្បាយខ្លះ ព្រោះជាសភាពមានការទាក់ទងនឹងព្រះពុទ្ធសាសនា ដែលរដ្ឋកម្ពុជៈយើងបានប្រកាន់ខ្ជាប់ជាយូរមកហើយ លើគោលបីយ៉ាងគឺ ជាតិ, សាសនា, ព្រះមហាក្សត្រ ។ ហើយពាក្យថាព្រះមហាក្សត្រនេះទៀតសោត ក៏យើងមិនមែនចេះតែថាបានទៅតាមការនឹកឃើញនោះទេ ព្រោះពាក្យនេះមានន័យដល់ការលើកដំកើងព្រះអង្គម្ចាស់ជាព្រះរាជវង្ស ហើយជាក្សត្រធ្លាប់មានអភិនិហារកសាងច្រើនពីអតីតសម័យមកផង ទើបអាចព្រះអង្គ ត្រូវគេថ្វាយព្រះនាមថាជាព្រះមហាក្សត្រ ដែលមានប្រជាជនរាប់លាននាក់គោរពបូជាព្រះអង្គ

ទីបំផុតនេះ ទូលព្រះបង្គំតាងនាមសមាគមមិត្តពុទ្ធិកវិទ្យាល័យ សូមថ្វាយដោយសុទ្ធចិត្តនូវព្រះរាជកុសលដែលសមាគមបានកសាងមកជាច្រើនឆ្នាំហើយ សូមព្រះអង្គនឹងសម្តេចព្រះអគ្គមហេសីទ្រង់គង់ជាសុខក្នុងសិរីរាជសម្បទ នឹងសម្រេចផលតាមព្រះរាជបំណង នឹងបានទ្រង់ព្រះជន្មវែងលុះផុតព្រះជន្មាយុក្ស័យ បានរក្សាការពារសេចក្តីថ្ងៃថ្នូរនឹងការរុងរឿងនៃព្រះពុទ្ធសាសនាតទៅអនាគតកុំបីឃ្លាងឃ្លាតឡើយ ។

ជយោ ! ព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រិត្យ

ជយោ ! ព្រះមហាក្សត្រិយានី កុសុមៈ

ជយោ ! សតវត្សទី ២៥ នៃ ព. ស.

បណ្ណាធិការ



## ពុទ្ធទស្សនៈ (ក)

## បារមីទាំង ១០ គឺ៖

ទានំ សីលញ្ច នេក្ខម្មំ បញ្ញាវិរិយេន បញ្ចមំ

ខន្តី សច្ចមធិដ្ឋានំ មេត្តុបេក្ខាតិមេ ទស ។

១–ទានៈ ការឲ្យនូវទ្រព្យសម្បត្តិដល់បុគ្គលអ្នកខ្វះខាត់ខ្សត់ខ្សោយ និងបុគ្គលគួរអនុគ្រោះ ។

២–សីលៈ ការរក្សាសេចក្ដីសុចរិតក្នុងត្រៃទ្វារ បានដល់ការរក្សាសីល៥ អស់កាលជានិច្ចជាដើម ។

៣– នេក្ខម្មៈ ការចេញចាកកាម លះទ្រព្យសម្បត្តិក្រុមគ្រួសារ និងសេចក្ដីសុខគ្រប់យ៉ាងក្នុងឃរាវាស ហើយចេញបព្វជ្ជា ។

៤–បញ្ញា ការដឹងកន្លងរបស់ដែលគួរដឹង ដូចជាល្អ-អាក្រក់ ដឹងបុណ្យដឹងបាប ជាដើម ។

៥–វិរិយៈ សេចក្តីព្យាយាមខ្នះខ្នែង ។

៦– ខន្តិៈ ការអត់ធន់ ចំពោះហេតុដែលគួរអត់ ដូចជាការអត់ធន់ចំពោះពាក្យពោលជេរប្រទេចត្មះតិះដៀល ។ល។ មិនពោលមិនប្រទូស្តវិញ ។

៧– សច្ចៈ សេចក្តីពិតត្រង់, ចិត្តទៀងត្រង់, ឬការបំណងស្វែងរកសេចក្តីពិត;

៨– អធិដ្ឋានៈ បានដល់ការតាំងចិត្តខ្ជាប់ខ្ជួន; ឬមាំមួនឆ្ពោះករណីយនោះៗ;

៩– មេត្តា ការផ្សាយមេត្តាទៅដល់សព្វសត្វនៅក្នុងទិសទាំងពួង ។

១០– ឧបេក្ខាៈ ការសំឡឹងពៃយ៉ាងស៊ប់ស្ងួនចំពោះសព្វសត្វទាំងពួងឥតរើសមុខរើសឋានៈ ដោយការប្រាសចាកសោមនស្សនិងទោមនស្ស ។

ដែលបានពោលដល់បារមី ដោយសេចក្តីសង្ខេបមកនេះ ជាសេចក្តីអធិប្បាយទូទៅ; តែបើវិនិច្ឆ័យចំពោះអត្ថបទនៃព្រះពុទ្ធជាម្ចាស់វិញនោះ ដូចមានន័យតទៅ៖

– " ព្រះអង្គបង្អោនព្រះជន្មទៅ ដើម្បីជាប្រយោជន៍ដល់ប្រជាជនច្រើនដោយព្រះមេត្តា ចាត់ជាទានបារមីនិងមេត្តាបារមី; "

– ស្តេចចេញសាងអភិនេស្ក្រមណ៍ ចាត់ជានេក្ខមបារមី;

– ទ្រង់សង្រួមក្នុងសីលធម៌សមគួរដល់ភេទបព្វជិត ចាត់ជាសីលបារមី,

– ទ្រង់បំពេញព្យាយាមនិងទ្រង់អត់ធន់ដល់សេចក្តីទុក្ខលំបាក ចាត់ជាវិរិយបារមីនិងខន្តិបារមី;

– ទ្រង់តាំងព្រះហឫទ័យខ្ជាប់ខ្ជួនក្នុងឧបដិបទា, ដើម្បីស្វែងរកសេចក្តីពិតមែន ចាត់

ជាអធិដ្ឋានបារមី នឹងសច្ចបារមី;

— ទ្រង់រក្សាព្រះហឫទ័យទុកមិនឲ្យវិការៈផ្លាស់ប្តូរ ដោយសេចក្តីសោមនស្ស ទោមនស្ស ចាត់ជាឧបេក្ខាបារមី;

— ប្រាជ្ញាធ្វើឲ្យព្រះអង្គភ្ញាក់រឭក ដឹងនូវកាល ហើយអាចទ្រង់ក្រឡេកឃើញនូវដំហានទៅខាងមុខមិនទញ់ទាល់ នាំព្រះអង្គចេញអំពីកិរិយាដែលមិនមែនជាផ្លូវ ជាដំណើរទៅក្នុងបដិបទា ដែលជាផ្លូវឈានទៅកាន់ការចាក់ធ្លុះនូវអនុត្តរសម្មាសម្ពោធិ-ញាណ ចាត់ជាបញ្ញាបារមី ។

បារមីទាំង ១០ នេះ តាមតម្រាបូពណាលោកពោលទុកថា ព្រះពោធិសត្វ ត្រូវបំពេញជាលំដាប់ច្រើនជាតិ ទាល់តែគ្រប់បរិបូណ៌ហើយកាលណា, កាលនោះ ទើបបានត្រាស់ដឹងជាអរហន្តសម្មាសម្ពុទ្ធ, ក្នុងទីនេះក៏ដូចគ្នា ។ តែគួរនឹងសន្និដ្ឋានថា លោកសំដែងមកប៉ុណ្ណោះ ដើម្បីបំណងយកជាគ្រឿងប្រៀបធៀប គឺបារមីខ្លះព្រះអង្គអាចបំពេញបានបរិបូណ៌ កាលនៅជាគ្រហស្ថ បារមីខ្លះព្រះអង្គបំពេញបានបរិបូណ៌ កាលស្តេចយាងចេញបព្វជ្ជា ។ ដែលគួរនឹងសន្និដ្ឋានយ៉ាងនេះ ព្រោះតាមផ្លូវសៃយសាស្ត្រប្រកាន់ថា: អ្នកដែលបានបួសហើយនោះ ទើបបានឈ្មោះថា "ទ្វិជ" អ្នកកើតពីរដង គឺកំណើតអំពីគភមាតាម្តង, កំណើតកាលដែលបានបព្វជ្ជាម្តងទៀត ។ ដូច្នេះអ្នកដែលនៅមិនទាន់បានបព្វជ្ជា ឈ្មោះថា អ្នកនៅក្នុងជាតិទី ១, លុះដល់បព្វជ្ជាហើយទើបដល់ជាតិទីពីរ, ។ ការបំពេញបារមីផ្សេងៗ អាចធ្វើបានក្នុងជាតិទី ១ ខ្លះ តែត្រូវបានកំណើតក្នុងជាតិទីពីរជាមុនសិន ទើបនឹងអាចបំពេញឲ្យបរិបូណ៌គ្រប់ទាំង ១០ ប្រការបាន ។

បំណែកព្រះពុទ្ធជាម្ចាស់របស់យើង កាលដែលព្រះអង្គនៅមិនទាន់បានស្ដេចចេញបព្វជ្ជានៅឡើយ ក៏ទ្រង់បានបំពេញព្រះបារមីច្រើនប្រការហើយពិត, ព្រោះព្រះអង្គជានាយ, ជាម្ចាស់ ទាំងព្រះវរាជបិតា ក៏ទ្រង់គ្រប់គ្រងទុកឲ្យបានស្ថិតនៅជាមហាក្សត្រិយ៍តាមពាក្យទំនាយរបស់ឫសី; ។ បើយ៉ាងនេះឃើញថា ទ្រង់បានបំពេញទសពិធរាជធម៌មកជាប្រក្រតីពិត ។

ធម៌ ១០ ប្រការដែលពោលក្នុងទីនេះ ជាធម៌សម្រាប់បុគ្គលជាម្ចាស់ ជាធំ ជានាយត្រូវប្រព្រឹត្ត, ទើបបានឈ្មោះថា "ទសពិធរាជធម៌" (នៅមានត)




## បុណ្យព្រហ្មទាន

ក្រោមព្រះរាជាធិបតីភាព

ព្រហ្មទានជាទានយ៉ាងវិសេស ដែលសមាគមមិត្តពុទ្ធិកវិទ្យាល័យ បានចាប់ផ្ដើមឡើងជារាល់ឆ្នាំ សម្រាប់ផ្ដល់រង្វាន់សមណនិស្សិតដែលប្រឡងចេញពីពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត, ពិធីនេះចាត់ទុកជាបវេណីមួយដែលសមាគមមិនដែលលះបង់ ។

ថ្ងៃទី ២៥ កុម្ភៈ ១៩៥៦ វេលាម៉ោង ១៨.,៣០ នៅវត្តពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត គេឃើញពុទ្ធបរិស័ទទាំងគ្រហស្ថនិងបព្វជិតមកជួបជុំពាសពេញបរិវេណ ទាំងមូល ។ ដល់ម៉ោង ២០,៣០ នាទី គណៈកម្មការរៀបចំបុណ្យ ដែលមានលោក ចាប-ពិន ជាអ្នក

ជំនាញការក្នុងទីនោះ កំចាប់ផ្ដើមនិមន្តសមណៈនិស្សិតទាំងអស់ដែលទើបនឹងប្រឡងជាប់ ឲ្យសូត្រព្រះបរិត្ត ។ ម៉ោង ២១ និមន្តព្រះតេជៈគុណពោធិវ័ង្សប្រធានហ្វានពុទ្ធិកវិទ្យាល័យ ព្រះសុភម្រឹត្យសំដែងធម៌ទេសនា ។



ថ្ងៃទី ២៦ កុម្ភៈ ម៉ោង ១៥,៣០ គេឃើញឥស្សរជនជាច្រើនរូបបានមករួមក្នុងពិធីនេះ ដែលសុទ្ធតែមានអត្តាប់ព្រហ្មទានផ្ទាល់ខ្លួនស្រាប់ផង ក្នុងចំណោមឥស្សរៈជនទាំងនេះគេឃើញគណៈរដ្ឋមន្ត្រី ដែលមានលោក អ៊ុំ ឈាង-ស៊ុន ជានាយក លោកប្រធានក្រុមប្រឹក្សាជាតិ លោកប្រធានរដ្ឋសភា លោកឧត្តមស្នងការបារាំងប្រចាំប្រទេសកម្ពុជា ដែលលោកមិនដែលលះបង់ព្រហ្មទានរបស់លោកជារៀងរាល់ឆ្នាំមក នៅរង់ចាំទទួលព្រះរាជដំណើរព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងឥស្សរៈជនដទៃទៀតជាច្រើន ។

ឥស្សរៈគ្រប់ថានៈក៏បានអញ្ជើញមកជួបជុំអស់ហើយ, ផ្នែកខាងគ្រហស្ថ, ផ្នែកខាងព្រះសង្ឃវិញគេឃើញសម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក សម្ដេចព្រះធម្មលិខិតឧត្តមប្រឹក្សា ជំណាងសម្ដេចព្រះសុធម្មាធិបតិសង្ឃនាយកគណធម្មយុត្តិ និងព្រះសង្ឃរាជាគណៈជាច្រើនអង្គ កំបានមករួមនឹងរង់ចាំទទួលព្រះរាជដំណើរក្នុងពិធីនោះដែរ ។ ពេល

ដែលសមណៈនិស្សិតកំពុងគង់ដំរៀបគ្នាជាជួរ លំដាប់ព្រហ្មទានក៏រៀបទៅតាមលំដាប់លេខ ម៉ោង១៦ក៏បានមកដល់ ព្រះរាជដំណើរនៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងក៏ស្ដេចយាងមកដល់ដែរ ដែលមានក្រុមក្មេងនឹងកងរក្សាព្រះអង្គចាំគាល់ធ្វើកិច្ច ។



ក្នុងព្រះរាជដំណើរនេះគេសង្កេតឃើញសហការីរបស់ព្រះអង្គគឺ សម្ដេចជហ្វាំងវរវៀងជ័យ, ឯ.ឧ.ឃឹម-ទិត, ឯ.ឧ.សម-សារី បានដង្ហែព្រះអង្គមកជាមួយផង ឥស្សរៈជនទាំងឡាយនឹងក្រុមឧបាសក-សិកា ក៏បានធ្វើគារវៈកិច្ចដោយគោរពចំពោះព្រះអង្គ ។

ម៉ោង១៦;១៥នាទី លោកប៉ាយ-បុក ប្រធានសមាគមមិត្តពុទ្ធិកវិទ្យាល័យចាប់ថ្លែងសុន្ទរកថាមួយយ៉ាងក្បោះក្បាយ ដែលមានសេចក្ដីដូចតទៅ ។ (នៅមានត)

X

X X

ការបំបួសកុលបុត្រ (ត)

## ប្រយោជន៍នៃអដ្ឋបរិក្ខារ

បរិក្ខារៈគ្រឿងប្រដាប់សម្រាប់ប្រើប្រាស់របស់អ្នកបួសមាន៨យ៉ាងគឺ ចីពរ ស្បង់ សង្ឃាដី បាត្រ កាំបិតម្ហុល វត្តពន្ធបង្កេះ ធមក្រក (តម្រងទឹក) ។

ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតគ្រឿងបរិក្ខារទាំង៨នេះដល់អ្នកបួស ដើម្បីទីនីរក្សាបំពាក់កាយ ទីនីរក្សាបំពាមផ្ទៃបានស្រួល ។

ហេតុនេះខ្ញុំសូមអធិប្បាយអំពីបរិក្ខារទាំង៨ឲ្យឃើញប្រយោជន៍ ស្រួលច្បាស់លាស់ទៀតតាមវិតបំណងនៃព្រះបរមគ្រូដែលទ្រង់អនុញ្ញាតទុកមក ។ បណ្ដាបរិក្ខារទាំង៨ គ្រង់បរិក្ខារមួយ ៗ មានប្រយោជន៍ពីរ ៗ ដូចតទៅនេះ ៈ

## ត្រៃចីវរ

ចីពរ ស្បង់ សង្ឃាដី មានប្រយោជន៍២យ៉ាងគឺកាយបរិហារ្យ គ្រឿងរក្សាបំពាមកាយ១ កុច្ឆិបរិហារ្យ គ្រឿងរក្សាបំពាមផ្ទៃ១ ។

កាលភិក្ខុស្លៀកដណ្ដប់ត្រៃចីវរ ចេញដើរទៅក្នុងបន្ទោះស្រុកត្រៃចីវរនោះហៅថា "កាយបរិហារ្យ" គ្រឿងរក្សាបំពាមពង់កាយ ។

កាលភិក្ខុដើរទៅដល់ជាស្រែកទឹក ហើយយកដាយចីវរត្រងទឹកឆាន់ឬក៏យកចីវរវេចផ្លែឈើតូចធំមានផ្លែស្វាយទីនីផ្លែលុតជាដើមក្នុងកាលដែលទាយកប្រគេនមកត្រៃចីវរនោះហៅថា "កុច្ឆិបរិហារ្យ" គ្រឿងរក្សាបំពាមផ្ទៃ ។

## បាត្រ

កាលភិក្ខុយកបាត្រដងទឹកស្រង់ឬដងទឹកស្រោចប្រស់ព្រំកុដិជាដើម បាត្រនោះហៅថា "កាយបរិហារ្យ" គ្រឿងរក្សាបំពាមពង់កាយ ។ កាលភិក្ខុយកបាត្រទទួលអាហារភោជនមកឆាន់ បាត្រនោះហៅថា "កុច្ឆិបរិហារ្យ" ជាគ្រឿងរក្សាបំពាមផ្ទៃ ។

(នៅមានត)

# ប្រវត្តិសង្ខេបនៃនាលន្ទា (ត)

មានព្រះបដិមាករ , រូបព្រះពោធិសត្វ, រូបទេវតា, រូបព្រហ្មជាដើម ៗ ពីខាងដើមមានព្រះវិហារមួយធំ សាងជាប់នឹងគ្រឹស្ថានសិក្សា ៗ ព្រះវិហារនេះ មានចម្លាក់របនាល្អចំឡែក សឹងឆ្លាក់អំពីថ្មទាំងអស់ ៗ នៅជុំវិញព្រះវិហារ នឹងចេតិយ



NALANDA

ទាំងនោះ មានចេតិយតូច ៗ អមព័ទ្ធពាសពេញគ្រប់បរិវេណចេតិយ គណនារាប់ដល់រយពាន់ ៗ មានវត្ត, ព្រះវិហារ, ចេតិយ ជាច្រើនតាំងនៅឃ្លាតអំពីបរិវេណនៃមហាវិទ្យាល័យ ចម្ងាយ ១០០ម. ខ្វះ, ២០០ ម. ខ្វះ, ៥០០ ម. ខ្វះ, ១-២-៣-៤ គ.ម. ខ្វះ គ្រប់ទិសជុំវិញមហាវិទ្យាល័យ ៗ

កិត្តិស័ព្ទរបស់មហាវិទ្យាល័យនាលន្ទាជំនាន់នោះ បានរន្ទឺខ្ទរខ្ទាយទៅគ្រប់ប្រទេស ប្រាកដច្បាស់ដល់អ្នកប្រាជ្ញនៃជាតិផ្សេង ៗ ៗ កវីនិស្សិតទាំងឡាយ ត្រាច់ស្កាត់ពី

ប្រទេសផ្សេង ៗ គឺប្រទេសចិន, ជប៉ុន, ទីបេត៍; កូរ៉េ, ម៉ុងហ្គោលី, ខ្មែរ, ជ្វា, លង្កា, អាស៊ីកណ្ដាល ។ល។ មកកាន់មហាវិទ្យាល័យនាលន្ទាដើម្បីស្រូបជញ្ជក់យកវិជ្ជានៅទីនេះ ។ ព្រះពុទ្ធសាសនាដែលអាចផ្សាយចូលទៅក្នុងប្រទេសចិន, ទីបេទ៍, ម៉ុងហ្គោលី ជប៉ុន ជាដើមបាន ដោយអំណាចឥទ្ធិពលនៃមហាវិទ្យាល័យនាលន្ទានេះដែរ ។ មហាវិទ្យាល័យនេះ គឺជាប្រភពដើមកំណើតនៃលទ្ធិមហាយាន ។ មានអ្នកប្រាជ្ញសំខាន់ៗ ខាងលទ្ធិមហាយានបានមកសិក្សាក្នុងមហាវិទ្យាល័យនេះដូចបណ្ឌិតឈ្មោះ នាគជុន, អស្សឃោសៈ, ថាំងសាំងចាង, ហ្វាហៀនជាដើម ។មហាវិទ្យាល័យនាលន្ទា មិនមែនគ្រាន់តែមហាវិទ្យាល័យសំរាប់សាសនាប៉ុណ្ណោះទេ គឺជាមហាវិទ្យាល័យសិល្បកម្ម និងវិទ្យាសាស្ត្រផង ។ មានការសិក្សាឆ្លាក់របនាដូចរូបបដិមាករ, រូបព្រះពោធិសត្វ, រូបទេវតា, រូបសត្វផ្សេង ៗ និងគ្រឿងប្រើប្រាស់ច្រើនបែបច្រើនយ៉ាង វិចិត្រអំពីដែក, ថ្ម, ទង់ដែងជាដើម ដែលជារបស់មានតម្លៃនៃសិល្បៈឥណ្ឌាក្នុងយុគនោះ ។ មានបង្រៀនតាំងពុទ្ធសាសនា សាសនាព្រាហ្មណ៍, វណ្ណគតិ, តក្កវិជ្ជា, ទស្សនវិជ្ជា, គីមីវិជ្ជា ហេតុវិជ្ជា, ស័ព្ទវិជ្ជា, វេជ្ជសាស្ត្រ, គាពសាស្ត្រ និងទិតសាស្ត្រព្រមទាំងវិជ្ជាយោគីទៀតផងៗ រដ្ឋាភិបាលបានជួយឧបត្ថម្ភទំនុកបំរុងគ្រប់យុគគ្រប់សម័យ ។

មហាវិទ្យាល័យនាលន្ទានេះបានចំរើនរុងរឿងមានឥទ្ធិពលខ្លាំងក្លាយ៉ាងនោះ ក៏គេចមិនរួចអំពីការបង្គាប់នៃអនិច្ចតាមធំ, បានគង់ទ្រង់នៅចំនួន១ពាន់ឆ្នាំ ប៉ុណ្ណោះ, ក៏ត្រូវពួកសត្រូវបុកទំលាយបំផ្លាញអស់ ។ គឺគ្រាប្រមាណ ៧០០ ឆ្នាំបាយកន្លងមកនេះ ពួកមូស៊ីម (ឥស្លាម) បានលើកទ័ពមកវាយបំផ្លាញកំទេចចោលអស់ ។ មេទ័ពធំឈ្មោះ ភ័ខតិយារ (Ehakhatiyar) កាលលើកទ័ពមកដល់នាលន្ទា ឡៀកូនឈ្មោះខិលជី (Khilji) នាំទាហានសេះ ២០០ ចូលរុករាន បុកទំលាយមហាវិទ្យាល័យ, ដុតគ្រឹស្ថាន

សំណាក់របស់ព្រះសង្ឃ, ដុតបណ្ណាល័យ, វាយបំបាក់ព្រះចេតិយព្រះស្តូប, សម្លាប់ភិក្ខុសាមណេរនឹងពួកជនអ្នកនៅរួមក្នុងមហាវិទ្យាល័យនេះ ៗ និស្សិត នឹងសាស្ត្រាចារ្យទាំងឡាយណាដែលគេចរួចផុត ក៏រត់ចេញទៅនៅទីផ្សេង ៗ ៗ ឯមេទ័ពឈ្មោះ ខិលជី ក៏យឹតយកទីមហាវិទ្យាល័យនេះ ធ្វើជាបន្ទាយបណ្តោះអាសន្នរបស់ខ្លួន ៗ សម័យក្រោយមក កាលពួកមុស្លីមចេញអំពីទីនេះ ដោយជញ្ជូនយកទាំងទ្រព្យសម្បត្តិសំខាន់ ៗ របស់មហាវិទ្យាល័យអស់ទៅផង, មានជនពុទ្ធសាសនិកខ្លះមកជួសជុលបំពេញឡើងជាថ្មី បំរុងនឹងបណ្តុះពូជឡើងវិញ ប៉ុន្តែពួកហិណ្ឌូ (ព្រាហ្មណ៍) ប្រណែនដោយខ្លាចក្រែងពុទ្ធសាសនារុងរឿងឡើងជាថ្មី ក៏នាំគ្នាដុតបំផ្លាញបន្ថែមមុស់ទៅទៀត ហើយបង្គាប់ឲ្យចាំយាមបង្ខាំងមិនឲ្យពុទ្ធមាមកៈណាចេញចូលទៅមកបានឡើយ ៗ មហាវិទ្យាល័យនាលន្ទា ក៏សូន្យកិត្តិស័ព្ទ បាត់ឈ្មោះបាត់សម្លេងព្រមគ្នានឹងភិក្ខុសង្ឃ ដូចជាប្រទីបកំពុងត្រោលបំភ្លឺក្នុងរាត្រី ស្រាប់តែរលត់ភ្លឹបដោយអំណាចនៃខ្យល់ព្យុះបាត់សូន្យឈឹងនៅសល់តែគ្រឹះនៃគ្រឹះស្ថាន នឹងដុំឥដ្ឋដុំថ្មបាក់ រហូតដល់សព្វថ្ងៃ ៗ (នៅមានត)



[illegible] នៅមហាវិទ្យាល័យនាលន្ទាចាស់
NALANDA



# ពុទ្ធប្បវត្តិ

ដោយលោក កែវ-ហង្ស អតីតចាងហ្វាងនៅឃុំសួងស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

រៀបរៀង

បទព្រហ្មគីតៈ

អហំសូមនមស្ការ ទន់សិរសាហត្ថប្រណម្យ ក្រញួក្រាបថ្វាយបង្គំ
គុណឧត្តមកែវទាំងបី ។ សូមឲ្យមានតេជះ ក្ដីត្របះបញ្ញាស់សេចក្ដី
ដោយគុណរ័ត្នទាំងបី ដូចសេចក្ដីដែលខ្ញុំប៉ង ។ នឹងតែងពុទ្ធប្រវត្តិ

ជាកំណត់តទៅហោង អតីតហួសកន្ទង ខ្ញុំថែងបងជាកាព្យ ។
ខ្ញុំតែងរៀងនេះឯង បរចារថ្ងៃពីកាលគ្រា ចុះចាប់ផ្ទៃមាតា
លុះដល់គ្រាទ្រង់និព្វាន ។

កាលទ្រង់ចុះចាប់បដិសន្ធិ

រីអង្គពុទ្ធបិតា ពុទ្ធមាតាជាប្រធាន ត្រកូលសាក្យញាណ
ថ្ងៃថ្កើងថ្កានដ៏ឧត្តម ។ សោយរាជជាមហាក្សត្រ គ្រង់សម្បត្តិនគរធំ
កបិលព័ស្តុក្សាន្តិរម្យ ដ៏សក្តិសមទ្រព្យសែនកោដិ ។ ឯអង្គពុទ្ធបិតា
ទ្រង់នាមជាព្រះសុទ្ធោទន៍ មាតាទ្រង់នាមសោត ជាព្រះមាយាទេវី ។
គង់ក្នុងប្រាសាទរ័ត្ន ល្អវិចិត្រឥតមានពីរ ក្បីប្រាលសព្វទិសទី
បមនារីគាល់ជុំជិត ។ យប់មួយព្រះមាយា ទ្រង់និទ្រាយល់និមិត
សុបិនឃើញជាក់ពិត ដំរីសភ្លុកប្រាំមួយ ។ ចុះចាកពីអាកាស
ល្អឧភាសដូចគេសួយ ចូលផ្ទៃនាងគ្មានព្រួយ ជ្រែកតាមដោយដំនីរស្តាំ ។
ព្រឹកឡើងព្រះសុទ្ធោទន៍ ចង់ពិសោធន៍តាមបំណាំ ឲ្យអាមាត្យហៅព្រាហ្មណ៍
មកឲ្យទាយនូវនិមិត ។ លុះព្រាហ្មណ៍មកដល់ហើយ ពុំក្តើយហើយគន់គិត
តាមហេតុនៃនិមិត ប្រាកដពិតជាទ្រង់គភ៌ ។ ទាយថាព្រះរាជបុត្រ
អង្គបរិសុទ្ធិមានលក្ខណ៍ល្អ គ្រប់យ៉ាងហើយទាយត គង់នគរបានស្តេចចក្រ ។
បើចេញពីនគរ ស្វែងរកធម៌ជៀសអបល័ក្សណ៍ ត្រាស់ដឹងប្រាកដជាក់
ជាព្រះពុទ្ធមួយព្រះអង្គ ។ ប្រោសសត្វក្នុងត្រៃលោក ទីពឹងជ្រកតែងស្រោបស្រង់
ញុំាងចិត្តឲ្យថូរផង់ ដោយព្រះអង្គករុណា ។ កាលអង្គព្រះបមមកុដ

រៀបច្យុតិចាកតុសិតា ទ្រង់ផ្ដាំទុកដាក់ការ នឹងព្រះសិអារ្យសំដែងធម៌ៗ
ប្រោសអស់ពួកទេវបុត្រ នៅតុសិតតាំងនាមករណ៍ ញុំាងចិត្តឲ្យបានល្អ
ជាដំណាងដួសព្រះអង្គ ។ រីគិកព្រះមាយា ទសមាសាគ្រប់ហើយហោង
ព្រះទ័យនឹកប៉ុនប៉ង បំណងទៅសួរបិតា ។
មាតាក្នុងនគរ ទេវទហ៍ពជសេមា នាំអស់ពួកសេនា-
មាត្យសេវការនាងគង់វរ ។ ហែហមព្រះនាងទៅ ចរតាមផ្លូវដោយសាទរ
ទៅដល់ព្រំនគរ ព្រៃលុម្ពិនីឈប់សេនា ។ សព្វថ្ងៃឮគេហៅ
រុម្មិណ្ដេប៉ាដារិយ៉ា ព្រះទ័យនាងជ្រះថ្លា យាងទៅឈរក្រោមដើមរាំងៗ
ព្រះនាងលើកហត្ថា ប៉ងប្រាថ្នាដោយកម្លាំង បង់ចាប់ទាញមែករាំង
ឯមែករាំងទន់ទាបឯង ។ ថ្វាយមកដល់ហត្ថា គ្រានោះណាអស្ចារ្យស្ដែង
គ្មានឈឺឲ្យចំបែង ប្រសូត្ររាជបុត្រា ។ ឯព្រះរាជឱរស
ប្រសូត្រនោះឥតឧបមា ឲ្យឃើញហេតុអស្ចារ្យ គ្មានប្រឡាក់អ្វីសៅហ្មង ។
ពេលនោះមានទរទឹក ធ្លាក់សន្ទឹកចុះមកហោង ស្រោចស្រពព្រះនាងផង
បុត្រថ្លៃកន្លងជាអស្ចារ្យ ។ កាលព្រះពោធិសត្វ ចាកគភ៌ផ្ទាត់ព្រះមាតា
មានព្រហ្មបួនរូបា យកសំណាញ់មាសទទួល ។ ព្រមទាំងស្ដេចចតុលោក
ចូលមូលមកដោយស្រុសស្រួល យកស្បែកឈ្លូសទទួល ដាក់សំរួលកោសេយ្យថ្មី ។
ឯអង្គពោធិសត្វ ឈរព្រះបាទលើផែនដី ក្ដោះក្រឡេបូពិទិសទី
ហើយក្សត្រថ្លៃឈានបាទា ។ ប្រាំពីរជំហានគត់ មានទេវបុត្រនឹងព្រហ្ម
បាំងក្លស់សៃលីលា អមអង្គាក្រោយពុំឈប់ ។

ព្រះអង្គពោះនេត្រា ទិសនានាដោយគ្រប់សព្វ ទ្រង់បញ្ចេញសូរស័ព្ទ
វាចីគេចតទៅថា ។ "ខ្លួនអញជាកំពូល លោកទាំងមូលទាំងប៉ុណ្ណា
ជាច្បងលើលោកា គ្មានអ្នកណាធំស្មើឡើយ ។ កំណើតអញជាន់នេះ
ផុតរបេះខាងចុងហើយ ទៅមុខគ្មានទៀតឡើយ ចេញផុតហើយពីអវិជ្ជា" ។
ឯអស់សេវកាមាត្យ ទិព្វឃ្លាតក្រាបវន្ទា អញ្ជើញព្រះមាយា
ទៅកបិលព័ស្តុរាជសោមា ។ ហែអង្គព្រះរាជបុត្រ ថ្ងៃបរិសុទ្ធផុតលោកា
ទៅថ្វាយព្រះបិតា ឲ្យបានជ្រាបសព្វសេចក្តី ។ ឯនាងព្រះមាយា
រាជមាតាបមពិសី ប្រសូត្រថ្មើមថ្ងៃ ប្រាំពីរថ្ងៃទីវង្គត ។
ទៅកើតតុសិតា អង្គបុត្រាថ្ងៃបរិសុទ្ធ បិតាតែងផ្គង់ផ្គត់
ដោយហ្មត់ចត់ជាប្រក្រតី ។ ឲ្យម្នាងមីងរក្សា នាមឈ្មោះគោតមី
ថ្នាក់ថ្នមបមលោមបី ពេញព្រះទ័យដោយស្មោះស្ម័គ្រ ។ (នៅមានត)

---

# ស្ថានការណ៍នៅសហភាពភូមា

ដោយមហា ឋោង-ទិត សមណនិស្សិតនៅធម្មទូតមហាវិទ្យាល័យក្រុងរ៉ង្គូន (ភូមា)

សូមលើកយកស្ថានការណ៍ខ្លះៗ ដែលបានទស្សនាដោយជាក់ច្បាស់នៅទីក្រុងរ៉ង្គូន សហភាពភូមា ។ ស្ថានការណ៍ដែលគួរលើកយកមកត្រងជាងលាតលា សរឲ្យឃើញជាក់ច្បាស់នូវសិលធម៌ និង អារ្យធម៌ វឌ្ឍនធម៌ ដែលជាស្នាដៃនៃប្រជាជនសហភាពភូមាមានយ៉ាងស្អានណាស់ តែក្នុងទីនេះ សូមលើកយកគ្រាន់ការណ៍ដែលសំខាន់ចំនួន ១៥ ១- មកថែងដើម្បីជាទិដ្ឋានុគតិ និង ជាគ្រឿងវិនិច្ឆ័យ ជាហេតុនាំឲ្យភ្ញាក់គំនិតគម្រើកប្រាជ្ញាដាស់ស្មារតីដូចតទៅនេះៈ

១- អំពីបូជនីយដ្ឋាន នៅក្រុងរង្គូន សហភាពភូមា  មានបូជនីយដ្ឋានច្រើនកន្លែងណាស់, បូជនីយដ្ឋានទាំងនោះ ប្រតិស្ឋាននៅតាមក្រុងក៏មាន តាមនិគមជនបទក៏មានប្រតិស្ឋាននៅលើទីដីទំនាប-ទីទួលក៏មាន នៅលើកំពូលភ្នំតូចធំក៏មាន ៗ បណ្ដាបូជនីយដ្ឋានទាំងនោះ បូជនីយដ្ឋាន ដែលឧត្តុង្គឧត្តមជាងគេ ស្ថិតនៅនាទិសឧត្តរនៃក្រុងរង្គូន គឺចេតិយ "ស្វេតគង់„, នៅចំពាក់កណ្ដាលទីក្រុង  មានចេតិយ ១ ខ្នងទៀត គឺចេតិយ "ស្វូឡេ„ (នៅក្បែរវេដ្ឋកា); នៅទិសបូព៌ានៃចេតិយនេះ  មានចេតិយ ១ ខ្នងទៀត គឺចេតិយ ពោធិតថោង„ ៗ នៅសង្កាត់ខេត្ត ក្នុងទិសទក្សិណនៃមហាបាសាគូហា មានចេតិយ ១ ខ្នងទៀត គឺ"កក្កាអេចេតិយ; ឬ លោកសន្តិចេតិយ,„  នៅមានចេតិយច្រើនកន្លែងណាស់តែមិនជាធំដុំណាស់ណាទេ  នេះចំពោះតែនៅទីក្រុងរង្គូន ៗ

១ទៀត បូជនីយដ្ឋាន ទីងជាវត្ថុដ៏វិសេសវិសាលទៅទៀត មានស្ថិតនៅឯក្រុងមន្ដលេ  ដែលជាបូរាណដ្ឋាននៃសហភាពភូមា ៗ ទីក្រុងចាស់នោះ ស្ថិតនៅក្នុងទិសឦសាននៃទីក្រុងរង្គូន ចម្ងាយ ៤៦០ មីល៍  គេអាចធ្វើគមនាគមន៍ទៅទស្សនាការបូជនីយដ្ឋានទាំងនោះ ដោយអាកាសចរក៏បាន ដោយរថយន្តឬកាណូតកុប៉ាល់ក៏បាន តែការធ្វើដំណើរដោយអាកាសយានឬអយស្ម័យយានជាការងាយជាង មិនសូវពិបាកបើធ្វើដំណើរទៅតាមអយស្ម័យយាន  ត្រូវឈប់សម្រាកដេកផ្លូវ១រាត្រីត្រង់តម្បន់មួយហៅថា ... ៗ

(នៅមានត)

# លិខិតសមណនិស្សិតយើង

ភិក្ខុវរបណ្ឌិតោ ( អាំ-សួន ហៅ ហម )

វិជ្ជាស្ថាននាលន្ទា ថ្ងៃទី ៩ កុម្ភៈ ១៩៥៦

ចំរើនពរមកលោកបណ្ណាធិការទស្សនាវដ្ដីមិត្តសាលាបាលី

សូមជ្រាប ។

ដោយយល់ឃើញថានឹងបានជាជំនួយដល់ទស្សនាវដ្ដីមិត្តសាលាបាលី និងដល់និស្សិតខ្មែរអ្នកសិក្សាភាសាអង់គ្លេស នោះអាត្មាបានព្យាយាមជ្រើសប្រែពាក្យនិងប្រយោគរចនាវិលាស (idioms) នៃភាសាអង់គ្លេសផ្ញើមកជូន ដើម្បីចុះផ្សាយក្នុងទស្សនាវដ្ដីតទៅ ដូចបែបសជ្ឈាយនៈទី ១ ទី ២ ដែលផ្ញើមកនេះ ។ និងមានប្រហែលជាង ៤០ សជ្ឈាយនៈទើបចប់ ។ តើអាចចុះផ្សាយបានឬទេ? បើបានក្នុងមួយភាគៗអាចចុះផ្សាយបានប៉ុន្មានសជ្ឈាយនៈ ( ១ ឬ ២ )? អាត្មានឹងព្យាយាមសរសេរផ្ញើមកជូនចុះផ្សាយគ្រប់ៗភាគតទៅ ។ ទស្សនាវដ្ដីចេញកាលខែដូចពីដើមឬ?

សូមមេត្តាតបដោយសំបុត្រទៅអាត្មាវិញ ម្យ៉ាងទៀតសូមមេត្តាឲ្យផ្ញើទស្សនាវដ្ដីទៅឲ្យអាត្មាអានផង ដើម្បីបានដឹងរឿងផ្សេងៗ និងដើម្បីបានដឹងរបៀបនៃការនិពន្ធរឿងនោះផង ។

ម្យ៉ាងទៀតសូមលោកជួយពិនិត្យពាក្យថា៖ (idioms) ដែលអាត្មាប្រែថា “រច-

នាវិលាសវាក្យៈ„នោះសមឬទេ? ខ្មែរយើងធ្លាប់ប្រែថាម៉េច? បើគេធ្លាប់ប្រែថាយ៉ាងណា មានសេចក្ដីសមរម្យល្អនោះ សូមតែទៅតាមគេយ៉ាងនោះផងចុះ ។ តែបើគេប្រែតាមសៀមថា"ភាសាសំនួន„ យ៉ាងនេះអាត្មាពុំសូវពេញចិត្ត, សូមប្រើ "របនាវិលាសវាក្យ„ វិញល្អជាង ។

ក្នុងវចនានុក្រមអង់គ្លេស-បាលីរបស់លោកគ្រូពុទ្ធទត្ត (លង្កាទ្វីប) សព្ទ(idioms) នេះមានន័យពីរយ៉ាងគឺ:"របនាវិលាស„និង"ភាសារីតិ„ ។ អាត្មាយល់ថា"ភាសារីតិ„ពិបាកអានហើយពិបាកយល់ផង, ទើបជ្រើសយក "របនាវិលាស„ ប្រើក្នុងទីនេះ ។

តែបើគេបង្កើតពាក្យដទៃ ដែលមានសេចក្ដីសមរម្យ ហើយដែលធ្លាប់ប្រើមកហើយនោះសូមតែទៅតាមគេផងចុះ ព្រោះកុំឲ្យមានការជំទាស់នឹងពាក្យចាស់ ។

ឮថាឈ្មោះសមាគមបានផ្លាស់ជា"សមាគមពុទ្ធិកវិទ្យាល័យ„ដូច្នេះមែនឬ?

សូមទទួលយកនូវសេចក្ដីនឹករលឹកនឹងកតញ្ញូភាពដ៏ជ្រាលជ្រៅ អំពីអាត្មានឹងព្រះមហាមិត្តទាំងពីររូប !

ហត្ថលេខា

(ភិក្ខុវីរបណ្ឌិតោ អាំ-សួន ហៅ ហម)

# ENGLISH IDIOMS

(របនាវិលាសវាក្យ ភាសាអង់គ្លេស)

លោកអ្នកអានគង់បានជ្រាបស្រាប់ហើយថា ភាសាអង់គ្លេសជាភាសាមួយដែលគេនិយមប្រើស្ទើរតែគ្រប់ប្រទេស ៗ ដូចជាប្រទេសអាមេរិក, អូស្ត្រាលី, ឥណ្ឌៀ ជាដើមដែលជាប្រទេសធំៗក្នុងលោក គេច្រើនប្រើភាសានេះជាផ្លូវការ ៗ ដោយចំពោះប្រទេសអាមេរិក គេប្រើអង់គ្លេសជាផ្លូវការទាំងអស់ ៗ ជនជាតិអាមេរិកាំងបានបង្កើតពាក្យ វិចិត្រឆ្នៃប្រយោគនៃភាសានេះជាច្រើនសំរាប់ក្នុងប្រទេសខ្លួន ផ្សេងអំពីភាសាដែលជនជាតិអង់គ្លេសធ្លាប់ប្រើ ៗ ពាក្យរបនាវិលាស (Idioms) របស់អង់គ្លេសនិងរបស់អាមេរិកាំងមានប្លែកគ្នាជាច្រើនអន្លើ ៗ

កាលខ្ញុំនៅសំណាក់ក្នុងប្រទេសសៀម ខ្ញុំបានឃើញនិស្សិតជាតិសៀមម្នាក់ដែលទើបប្រឡងចេញបានថ្នាក់បរិញ្ញាឯក (Doctor) ពីប្រទេសអង់គ្លេសមកថ្មីៗ បានចូលទៅហាត់និយាយនឹងស្ដាប់ភាសាអង់គ្លេសជាមួយពួកអាមេរិកាំងទៀត ព្រោះស្ដាប់ប្រយោគរបនាវិលាសទំនៀងអាមេរិកាំងពុំសូវបាន ៗ

កាលបើគេនិយាយពាក្យត្រង់ៗ ប្រយោគត្រង់ៗ នោះ យើងអាចស្ដាប់បានងាយព្រោះអាចប្រែត្រង់ទៅតាមស័ព្ទបានសេចក្ដី, តែបើគេប្រើពាក្យឬប្រយោគរបនាវិលាសនោះ យើងពិបាកស្ដាប់ ពិបាកយកសេចក្ដីក្រៃពេក ព្រោះពាក្យថា «Idiom» (របនាវិលាស) នេះសំដៅសេចក្ដីថា “ពាក្យឬប្រយោគដែលពុំអាចឲ្យប្រែត្រង់តាមស័ព្ទបាន„ ៗ ឧទាហរណ៍ដូចពាក្យ «turn out» ក្នុងប្រយោគថា «She turns ont one room every day» ៗ «Turn» ប្រែថា “មួល; ត្រឡប់; បង្វែរ„; «out» ប្រែថា “ចេញ; ចេញក្រៅ; ខាងក្រៅ„ ដូច្នេះត្រូវប្រែថា “នាងនោះបង្វិលចេញក្រៅនូវបន្ទប់មួយរាល់ៗថ្ងៃ„

យ៉ាងនេះឬ ? បើប្រែយ៉ាងនេះបានសេចក្ដីថាម៉េច? ។ ជួនកាលខ្លះសំគាល់សេចក្ដីថា "នាងនោះចេញពីបន្ទប់មួយទៅបន្ទប់មួយរាល់ៗថ្ងៃ", យ៉ាងនេះរឹតតែខុសស្រឡះទៅទៀត ។

ក្នុងប្រយោគនេះពាក្យ «Turn out» ឲ្យអត្ថន័យថា «Chean» ត្រូវប្រែថា "បោសឬជូតសំអាត", គឺ: "នាងនោះតែងបោស-ជូតសំអាតបន្ទប់មួយរាល់ៗថ្ងៃ" ។ ពាក្យ «Turn out» នេះអាចឲ្យអត្ថន័យផ្សេងៗ ទៀត, នឹងលើកឧទាហរណ៍ក្នុងមេរៀនទី២ ។

ក្នុងសៀវភៅ, ទស្សនាវដ្ដី និងសារពត៌មានផ្សេងៗ ជាភាសាអង់គ្លេសអ្នកនិពន្ធចូលចិត្តប្រើប្រយោគរចនាវិលាសនេះច្រើនក្រៃពេក ។ ព្រោះហេតុនោះអ្នកអានដែលពុំសូវស្ទាត់ជំនាញខាងប្រយោគរចនាវិលាស តែងពោលថា "ប្រយោគខ្លះអានបានប្រែស័ព្ទបានសព្វគ្រប់, ប៉ុន្តែពុំយល់សេចក្ដីថាយ៉ាងម៉េច" ។ យ៉ាងនេះ ក៏ព្រោះតែប្រយោគនោះៗ ជាប្រយោគរចនាវិលាស ( Idiom ) ។ គ្រូបង្រៀនអង់គ្លេសខ្លះក្នុងស្រុកយើងដែលខ្ញុំធ្លាប់បានរៀនជាមួយ, ពុំសូវជំនាញខាងប្រយោគរចនាវិលាស ក៏គ្រាន់តែប្រែប្រថប់ស័ព្ទឲ្យ, ជួនកាលខ្ញុំយកមកអានទាំងពុំដឹងរឿង ។ ព្រោះហេតុនោះអ្នកសិក្សាបើចង់ចេះឲ្យសព្វគ្រប់ លុះតែឧស្សាហ៍អាន, ពិនិត្យ, ទន្ទេញ, ចំណាំពាក្យនិងប្រយោគរចនាវិលាសថែមទៀតដោយម៉ត់ចត់ ។

ខ្ញុំ, ដោយមានសង្ឃឹមថា នឹងបានជាជំនួយជាទីគាប់ចិត្តដល់អ្នកសិក្សា, នឹងខំព្យាយាមជ្រើសប្រែពីសៀវភៅច្បាប់ផ្សេងៗ ផ្ញើមកចុះទស្សនាវដ្ដីនេះតាំងពីមេរៀនទី១ ទី២ តរៀងទៅ ។

(នៅមានត)

# សុន្ទរកថា

## ដែលលោកប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋបានថ្លែងក្នុងឱកាស
## បុណ្យបំបួសកុលបុត្រជាតិអូស្ត្រាលីនៅវត្តឧណ្ណាលោម

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយកនឹងព្រះមហាថេរានុត្ថេរៈ

សូមជំរាបឯកឧត្តមអគ្គទូតទាំងឡាយ មានឯកឧត្តមអគ្គទូតប្រទេសអូស្ត្រាលីជាដើម ព្រមទាំងអស់លោកពុទ្ធបរិស័ទទាំងបុរស-ស្ត្រី

សូមជ្រាប ។

ខ្ញុំព្រះករុណា ខ្ញុំតាងនាមគណកម្មាធិការនាយកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋសូមទទួលអំណរចំពោះសម្តេច, ព្រះមហាថេរានុត្ថេរៈ ឯកឧត្តម-អស់លោកពុទ្ធបរិស័ទទាំងឡាយ ដែលបាននិមន្ត-អញ្ជើញមក ក្នុងពិធីបុណ្យបំបួសកុលបុត្រឈ្មោះ ស៊ុដនេយហ៊ិល្ល នេះយ៉ាងក្រៃលែង ។

ដូចបានជ្រាបហើយថាកុលបុត្រឈ្មោះស៊ុដនេយហ៊ិល្ល នេះជាតិអូស្ត្រាលីនៅប្រទេសអូស្ត្រាលី ជាកុលបុត្រមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាបានប្រាស្រ័យទាក់ទងនឹងព្រះតេជៈព្រះគុណ ព្រះពោធិវង្ស ចាងហ្វាងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត យូរក្រែលមកហើយ ថ្វីងថាកុលបុត្រនេះចង់ចូលមកសូមបួសរៀន ព្រះធម្មវិន័យព្រះពុទ្ធសាសនានៅប្រទេសខ្មែរ ។

ហេតុនេះហើយព្រះតេជព្រះគុណព្រះពោធិវង្ស បានបញ្ជូនរឿងនេះមកពុទ្ធិកសមា-គមកម្ពុជរដ្ឋ ឲ្យលៃលកសូមអនុញ្ញាតពីរាជរដ្ឋាភិបាលតាមសេចក្តីដែលឈ្មោះស៊ុដនេយ-ហ៊ិល្ល នេះស្ម័គ្រចិត្ត ។ ព្រះករុណាខ្ញុំតាងនាមពុទ្ធិកសមាគមកម្ពុជរដ្ឋ បានសូមរាជ

រដ្ឋាភិបាល តាមរយៈឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ជំនាន់រាជរដ្ឋាភិបាលមុននេះ ដែលមានសម្តេចព្រះឧបយុវរាជ ជាប្រមុខទ្រង់ក៏បានប្រោស ព្រះរាជទានឲ្យឈ្មោះស៊ុដនេយ-ហ៊ុល្យ នេះបួសជាសាមណេររៀនធម្មវិន័យព្រះពុទ្ធសាសនានៅក្នុងវត្តឧណ្ណាលោមតទៅ ។

អាស្រ័យដោយសេចក្តីយល់ព្រមនៃសម្តេចព្រះសង្ឃនាយក វត្តឧណ្ណាលោម ទាំងជួយទំនុកបំរុង រួមជាមួយនឹងព្រះតេជគុណព្រះពោធិវង្សផង ទើបនៅថ្ងៃសៅរ៍១កេចខែមាឃឆ្នាំមមែសប្តស័ក ព.ស.២៤៩៨(២៨-៥៦) នេះបានសម្រេចបំបួសឈ្មោះស៊ុដនេយ-ហ៊ុល្យ ជាសាមណេរ ដោយសម្តេចអនុគ្រោះធ្វើជាព្រះឧបជ្ឈាយ៍បានប្រទាននាមលោកសាមណេរអង្គនេះហៅថា «ធម្មរតនៈ» ។

បពិត្រព្រះមហាថេរានុត្ថេរៈ ឯកឧត្តមអស់លោកពុទ្ធបរិស័ទទាំងឡាយ ។

ចំពោះលោក "ធម្មរតនៈ" នាមដើម ស៊ុដនេយ-ហ៊ុល្យនេះគណកម្មាធិការនាយកនៃពុ. ពិ. ម. កូ. ក. បានខិតខំទំនុកបំរុង =

១– សូមអនុញ្ញាតរាជរដ្ឋាភិបាលឲ្យបួស

២– បានចេញអាហារូបករណ៍ ដោយចំណាយទ្រព្យ ពុ. ពិ. ម. កូ. ក. អស់ ១.៤០០រៀល, ប្រាក់នេះបានមកពីភាគទាននៃសមាជិកគ្រប់ប្រភេទ ព្រោះយល់ឃើញថាមុខជានឹងមានប្រយោជន៍ដល់ ពុ. ពិ. ម. កូ. ក. វិញក្នុងពេលយ៉ាងខ្លីៈ មុខជាល្បីកិត្តិនាម ពុ. ពិ. ម. កូ. ក. ចេញទៅប្រទេសអូស្ត្រាលី ថាបានទំនុកបំរុងសមាជិកពុទ្ធិកសមាគមនៃប្រទេសអូស្ត្រាលីត្រាតែបានបួស ។

លោកសាមណេរធម្មរតនៈអង្គនេះបេះកាសាអង់គ្លេសយ៉ាងជំនាញ - ភាសានេះពួកសិស្សក្នុងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត្យ នឹងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជត្រូវការ

រៀនណាស់ ដើម្បីយកភាសានេះជាយានសម្រាប់ផ្សាយនូវអនុត្តរធម៌ របស់ព្រះសម្មាសម្ពុទ្ធចេញទៅប្រទេសនានា ជាការប្រពៃណាស់ ដោយលោកសាមណេរធម្មរតនៈអង្គនេះ បានសន្យាទទួលបង្រៀនភាសាអង់គ្លេស ដល់ពួកកូនសិស្សទាំងឡាយ ក្នុងសាលាទាំងពីរខាងលើនេះ ដោយឥតយកឈ្នួល, ន័យនេះហើយជាប្រយោជន៍ចំពោះ ពុ. ពិ. ម. កូ. ក. ក្នុងពេលយ៉ាងខ្លីពុំខានឡើយ ។

ម្យ៉ាងទៀតសូមជ្រាបថារាជរដ្ឋាភិបាលប្រទេសកម្ពុជាបានអនុញ្ញាតមុននេះ ឲ្យកុលបុត្រឈ្មោះ «ឡូរ៉ង់ប៉ូតែល» ជាតិបារាំងសែសឲ្យបួសជាសាមណេរដែរ ហើយសម្ដេចព្រះសង្ឃនាយកក៏បានធ្វើជាព្រះឧបជ្ឈាយ៍ បំបួសពីថ្ងៃអាទិត្យ ១កើតខែកត្តិក(១៦ តុលា ឆ្នាំ១៩៥៥,ប្រទាននាមហៅថា «អានន្ទ» ។

លោកសាមណេរទាំងពីរអង្គនេះ គង់នៅរៀនធម្មវិន័យ ក្នុងវត្តឧណ្ណាលោមតទៅ ។

នៅទីបញ្ចប់ខ្ញុំព្រះករុណាខ្ញុំ សូមលើកសួយនូវកុសលរាសី ដែលកើតឡើងអំពីបុណ្យផ្នួសនេះ ក្រាបបង្គំថ្វាយព្រះករុណាជាម្ចាស់ជីវិតលើត្បូងនិងសម្ដេចព្រះមហាក្សត្រិយានី ព្រមទាំងសម្ដេចព្រះឧបយុរាជ ជាប្រមុខនៃរាជរដ្ឋាភិបាល ដែលទ្រង់ប្រោសព្រះរាជទានព្រះរាជានុញ្ញាតឲ្យបំបួសលោកសាមណេរនេះ សូមស្ដេចថិតក្នុងសិរីរាជសម្បត្តិជាសុខសាន្តព្រះរាជវង្សានុវង្សតទៅ ។

សូមជូនចំពោះ ឯកឧត្តមអគ្គទូតទាំងឡាយដែលបានអញ្ជើញមកក្នុងបុណ្យបំបួសនេះ មានឯកឧត្តមអគ្គទូតអូស្ត្រាលីជាដើម ។

សូមជូនអស់លោកពុទ្ធបរិស័ទទាំងឡាយ ដែលបានមកក្នុងទីនេះទាំងប៉ុន្មានសូមឲ្យបានប្រកបដោយសេចក្ដីសុខ-ចំរើនក្នុងព្រះពុទ្ធសាសនាកុំបីឃ្លៀងឃ្លាតឡើយ ។



ខ្ញុំបាទទីលំនៅៗ ឃុំព្រែកអំពិល ស្រុកស្អាង (កណ្ដាល)

សូមជំរាបមកលោកប្រធានសមាគមមិត្តសាលាបាលី

សូមជ្រាប ៗ

សូមលោកប្រធានចុះអត្ថបទនេះក្នុងទំព័រទស្សនាវដ្ដីមិត្តពុទ្ធិកវិទ្យាល័យឲ្យបាន មាន សេចក្ដីដូចតទៅនេះ៖

ខ្ញុំបាទជាមនុស្សល្ងិតល្ងង់ពុំបានសិក្សាវិជ្ជាផ្លូវលោក-ធម៌នឹងគេ ទើបតែក្នុងព. ស. ២៤៩៨នេះ ខ្ញុំបាទក៏បានប្រគល់កាយថ្វាយខ្លួនជាឧបាសកមួយរូបនឹងគេ ក្នុងចំណោមឧបាសកទាំងអស់, តាំងពីពេលនោះមកខ្ញុំបាទក៏បានអានទស្សនាវដ្ដីមិត្តសាលាបាលី ជាមួយនឹងព្រះសង្ឃជាញឹកញយទៅ ក៏មានចិត្តបដិព័ទ្ធចំពោះអត្ថរសដ៏ចំណាញ់នៃទស្សនា-វដ្ដីជាពន់ពេក ប៉ុន្តែមិនបានសុំជាវប្រចាំឆ្នាំ ពីព្រោះខ្ញុំបាទជាមនុស្សទ័លក្រពេក ទើប

តែក្នុងខែមុននេះ ខ្ញុំបាទក៏បានសំណេះសំណាលជាមួយនឹងលោកអាចារ្យបង្រៀនបាលី អំពីការចំរើនលូតលាស់នៃការសិក្សាផ្លូវពុទ្ធសាសនា, លោកក៏មានពុទ្ធដីកាថា៖ មិនសូវចំរើនប៉ុន្មានទេ ។ ខ្ញុំបាទក៏សួរទៅទៀតថា: ហេតុដូចម្ដេចក៏បានជាមិនសូវចំរើន? ញោម! បានជាមិនសូវចំរើនពីព្រោះខ្វះខាងសម្ភារៈនឹងខាងផ្លូវចិត្តអំពីរាជការ, តាំងពីអាត្មាធ្វើអាចារ្យបង្រៀនបាលីបួនឆ្នាំហើយ ពុំដែលបានអ្វីសូម្បីតិចបន្តួច ជាអំណោយអំពីរាជការដល់សាលាបាលីរងនេះសោះ, មិនតែប៉ុណ្ណោះទេ សាលាបាលីរងហាក់ដូចជាសាលាក្រៅក្របខណ្ឌទៀតផង ។

ខ្ញុំបាទកាលបើបានស្ដាប់ពុទ្ធដីកាលោកដូច្នោះហើយ ក៏ស្រយុតក្នុងចិត្តពន់ពេកស្មើរតែស្រក់ទឹកភ្នែក នឹកឆ្ងល់ក្នុងចិត្តមិនដាច់ស្រេចថា:

ហេតុអ្វីក៏រាជការមិនជួយឧបត្ថម្ភផ្នែកខាងការសិក្សាផ្លូវសាសនាផង?

ឬមួយក៏រាជការ ទុកការសិក្សាខាងផ្លូវសាសនាជាមោឃៈ? បានជាបោះបង់ចោលយ៉ាងនេះ? ឬរាជការយល់ដូចម្ដេចទៅវិញ?

បើតាមយោបល់ខ្ញុំបាទជាមនុស្សល្ងង់យល់ថា រថដែលលឿនទៅបានអាស្រ័យចក្រ (កង់) ទាំងពីរទើបលឿនទៅបាន ប្រទេសមួយៗ ដែលមានវឌ្ឍនធម៌ទៅបានក៏តោងអាស្រ័យចក្រទាំងពីរដែរ ។

សូមលោកប្រធានមេត្តាជួយដោះស្រាយឲ្យខ្ញុំបាទអស់សេចក្ដីងឿងឆ្ងល់ក្នុងរឿងនេះឲ្យបានផង ។

អវសាន មុននឹងលាលោកប្រធាន អំពីទំព័រអត្ថបទនេះ សូមជំរាបអំពីការសិក្សាខាងពុទ្ធសាសនាដោយខ្លីឲ្យបានជ្រាបថា: ការសិក្សាផ្លូវពុទ្ធសាសនា ដូចជាក្នុងស្រុក

ស្ពានជាដើមមានវត្តប្រហែលជា២៥បណ្ដាលវត្តទាំងនេះ វត្តដែលធ្លាប់បានរៀនភាសា-បាលី១១វត្ត ក្នុងចំណោមវត្តទាំង១១នេះទៀតនៅតែវត្ត៥ទេដែលនៅសិក្សាដោយប្រឹងប្រែង ក្នុងឆ្នាំ១៩៥៥នេះ ។

តើលោកប្រធានយល់ថា ការសិក្សាខាងពុទ្ធសាសនាបានចំរើនយ៉ាងណា?

សេចក្ដីគោរពសូមអភ័យទោស

ហត្ថលេខា

វ៉ែត-សំអឿន

---

## សេចក្ដីកត់ហេតុមហាសន្និបាត (ត)

៤– សមាគមនេះកាលពីដើម យើងបានផ្ដើមធ្វើឡើងគឺ ដាក់នាមតាមសាលាបាលីជាន់ខ្ពស់ ឥឡូវនេះសាលាបាលីនោះបានកែប្រែនាមថា «ពុទ្ធិកមហាវិទ្យាល័យព្រះសុរាម្រឹត» ។ ហេតុដូច្នេះយើងសុំកែប្រែ «សមាគមមិត្តសាលាបាលីកម្ពុជរដ្ឋនេះថា «សមាគមមិត្តពុទ្ធិកវិទ្យាល័យកម្ពុជរដ្ឋវិញដើម្បីឲ្យស្របទៅតាមនាម «ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។

រឿងនេះមហាសន្និបាតពិភាក្សាអ៊ឹតប៉ត់អស់កាលដ៏យូរហើយបែកយោបល់ជាពីរ៖

ក)ថា "សមាគមមិត្តពុទ្ធិកវិទ្យាល័យ

ខ)ថា សមាគមពុទ្ធិកវិទ្យាល័យ" ។

មហាសន្និបាតភាគច្រើនបានយល់ព្រមឲ្យយកនាមខាងលើថា "សមាគមមិត្តពុទ្ធិកវិទ្យាល័យ"វិញ ដើម្បីឲ្យស្របទៅតាមគោលបំណងដើម ។

បន្ទាប់មកទៀតលោកម៉ៅ-មី សូមបញ្ជាក់យោបល់មហាសន្និបាតអំពីរឿងយកប្រាក់

សមាគមទៅដាក់ធនាគារជាតិ ឬក្នុងសមាគម ឬក៏អង្គការណាមួយដើម្បីឲ្យចម្រើនដល់សមាគម ។

លោកស្វាយ-ពាំ ឲ្យយោបល់ថា សូមកែត្រង់ពាក្យថាអង្គការនោះចេញពុំត្រូវទេ ព្រោះពាក្យថាអង្គការនោះ លុះណាតែរាជការបានទទួលស្គាល់ដោយត្រឹមត្រូវដូចជាធនាគារជាតិដូច្នោះដែរ ។ ក្នុងពេលនោះលោកប៊ុន-ហ៊ាន បានសុំស្នើអំពីច្បាប់ក្រមព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីក្នុងរឿងនេះចំពោះលោក ចាប-ស៊ុំ តើយ៉ាងណា? ។ (នៅមានត)

## រឿងតុក្កតាធ្វើពីទធិជាតិ (ត)

ព្រះរាជជនីមានបន្ទូលថា: "ឱ! គួរអនិច្ចាខ្លួនពេក; វេលានេះព្រះមហាក្សត្រទ្រង់ជ្រាប" ហើយថា ទ្រង់នឹងបានព្រះរាជបុត្រមួយព្រះអង្គ បានជាទ្រង់យកខ្សែនេះមកបំពាក់កឯង ឯងដឹងហើយតើថា មាតាមានតែអង្ករមួយក្ដាប់ក្នុងមួយថ្ងៃទុកជាព្រះស្ងោយ, មានកន្ទេលមួយតូចសម្រាប់ដេកហើយផ្ទាល់នឹងផែនដីផង, ក្នុងមួយឆ្នាំមានពេលតែមួយភ្លែតប៉ុណ្ណោះ ដែលមាតាត្រូវសប្បាយចិត្តរកអ្វីមកប្រៀបគ្មាន គឺជាវេលាដែលមាតាបានជួបព្រះភ័ក្ត្រព្រះមហាក្សត្រ ហើយបន្ទាប់ពីនោះមកមាតាក៏នៅជាទុក្ខដដែល ៗ ចុះបើសេចក្ដីកុហករបស់ឯងបានជ្រាបដល់ព្រះមហាក្សត្រទៅហើយនោះ មិនឈ្មោះថាឯងបានរំលាយនូវសេចក្ដីសុខមានសភាពដូចជាយល់សប្ដិ ដែលព្រះអង្គបានឲ្យដល់មាតាក្នុងមួយឆ្នាំម្ដងហើយឬ? ហេតុម្ដេចក៏ឯងយកដំណឹងមិនពិតនេះទៅទូលព្រះអង្គដែលជាហេតុនាំឲ្យមានទុក្ខទោសទៅអនាគត? កិច្ចការដែលឯងផ្ដើមនេះជាការគ្មានប្រយោជន៍នឹងជាទោសផង ។

"ឱ! ព្រះមាតា! ម្ដេចក៏ទ្រង់ព្រួយព្រះរាជហឫទ័យ?" ស្វាឆ្លើយ "សូមព្រះ

មាតាស្ដេចទ្រង់គង់នៅឲ្យស្ងៀមចុះ ក្នុងបីបួនខែទៀតគេនឹងនិយាយគ្រប់គ្នាថា "ព្រះរាជិនីទុក្ខរាទីរង់ចាំព្រះរាជបុត្រ" ។ កាលណាបើព្រះមហាក្សត្រស្ដេចយាងមកទតព្រះរាជបុត្រព្រះអង្គ ខ្ញុំម្ចាស់នឹងយកព្រះរាជបុត្រមួយដែលមានព្រះរូបល្អស្អាតដូចព្រះចន្ទពេញវង្ស មានសម្បុរក្រហមឆ្អៅដូចមាសមកដាក់លើជង្គង់ព្រះមាតា ហើយព្រះមាតានឹងបានបង្ហាញព្រះរាជបុត្រនោះទៅព្រះមហាក្សត្រ ។ ឥឡូវនេះសូមព្រះមាតាមេត្តាខ្ញុំ ពេលវេលាបេះវែកកន្ទុងទៅហើយ ខ្ញុំម្ចាស់ក៏កំពុងតែស្រេកឃ្លានយ៉ាងខ្លាំង តើព្រះមាតាមានអ្វីជាចំណីដល់ខ្ញុំម្ចាស់ដែរ" ។

— ស្វាជាទីពេញចិត្តរបស់មាតា...! នេះនែ! កែវទឹកត្រជាក់នឹងផ្លែឈើព្រៃ ដែលមាតាបានបេះទុកបម្រុងឲ្យអ្នក ចូរនាងបរិភោគតាមបំណងចុះ ។ ហើយព្រះនាងក៏រៀបចំណីទាំងនោះនៅលើបីរៈ (Pira)[១] ចាក់វែកកំវែលកពាក់កណ្ដាលឲ្យស្វា ។

## ការទាស់ឈ្លោះគ្នា

ព្រះរាជិនីសុខរាទីទ្រង់សុបិនអាក្រក់... នៅលើព្រះខែនមាសដែលនាងផ្ទុំ ហើយមានព្រះទ័យទោមនស្សយ៉ាងខ្លាំង ក្នុងពេលជាមួយគ្នានេះព្រះមហាក្សត្រព្រះអង្គក៏យាងមកក្រសាលនឹងព្រះនាង ហើយទ្រង់មានបន្ទូលថា:

" ព្រះប្អូន! នាងមានបានទទួលដំណឹងល្អទេឬ? ព្រះនាងទុក្ខរាទីនឹងប្រសូត្រព្រះរាជបុត្រមួយក្នុងពេលអនាគតនេះ! ពីដើមបងមានបារម្ភពន់ពេកចំពោះជោគវាសនានៃរាជអាណាចក្រយើងទៅថ្ងៃមុខ ដោយខ្វះរជ្ជទាយាទសម្រាប់តព្រះរាជវង្ស ។ ឥឡូវការព្រួយបារម្ភរបស់យើងនឹងរលត់បាត់តាំងពីពេលនេះទៅហើយ ។ បើព្រះនាងទុក្ខ

(១) បីរៈ (Pira) តុធំមួយដែលមានរចនាលាបពណ៌សម្រាប់ធ្វើតុបរិភោគ ។

ក៏មានព្រះរាជបុត្របងនឹងអភិសេកព្រះរាជបុត្រនោះជាព្រះមហាក្សត្រ, បើជាបុត្របងនឹងប្រគល់រាជសម្បត្តិនេះដល់ស្វាមីនាង ៗ ។ នាងជាទីពេញព្រះទ័យបង ពីដើមបងកើតទុក្ខឥឡូវនេះបងសប្បាយរីករាយហើយ យើងនឹងសប្បាយទាំងអស់គ្នា ៗ (មានត)

---

## ជ័យប្រាជ្ញ (ត)

អាមាត្យទាំងឡាយ ដែលទទួលព្រះឱង្ការពីព្រះមហាក្សត្រដើម្បីស្វែងរកអ្នកបំបាប់នោះក៏មិនអាចស្វែងរកអ្នកណាមួយសូម្បីម្នាក់បានឡើយ ហើយក៏នាំគ្នាទៅកាន់ព្រះរាជវាំងវិញ នាំសេចក្ដីនោះទៅក្រាបបង្គំទូលព្រះមហាក្សត្រ តាមការពិតដែលខ្លួនបានស្វែងរក ព្រះមហាក្សត្រក៏ត្រាស់សួរថា៖ ហេតុម្ដេចបានជារកមិនបាន ?

អាមាត្យ= សូមទ្រង់ព្រះមេត្តាប្រោស អ្នកបំបាប់ទាំងឡាយមិនហ៊ានលេងជាមួយនឹងអាជ័យសោះ មិនដឹងជាមានសភាពបែបណាទេ !

— ចូរឯងរាល់គ្នាទៅហៅអាជ័យមកមើល ?

"នែ អាជ័យ !" ព្រះមហាក្សត្រត្រាស់សួរ ហេតុម្ដេចក៏មិនមានអ្នកបំបាប់ណាមួយហ៊ានលេងជាមួយនឹងអាឯងសោះ ?

"សូមទ្រង់ព្រះមេត្តាប្រោស" កុមារជ័យឆ្លើយ "ពុំដឹងជាមានហេតុដូចម្ដេចទេ"

"បើដូច្នោះចូរឯងទៅហៅមហាតលិកនឹងអ្នកស្និតស្នាលទាំង៦ នាក់នោះមកមើល" ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ទៅអាមាត្យ

មហាតលិក នឹងអ្នកស្និតស្នាលក៏ចូលមកក្រាបបង្គំគាល់មួយរំពេច ហើយព្រះមហាក្សត្រក៏ទ្រង់ត្រាស់សួរថា នែ ! ឯងទាំងអស់គ្នានេះ តើអាជ័យវាប្រើដូចម្ដេចខ្លះ ?

អ្នកស្និតស្នាលនឹងពួកមហាតលិកក៏ក្រាបបង្គំទូលតាមដំណើរ ដែលខ្លួនបានធ្វើទាំង

ដល់ព្រះរាជាតាមការពិត ៗ

ព្រះរាជាកាលបើទ្រង់ព្រះសណ្ដាប់ហើយ ក៏ធ្វេងយល់ថា ឱ ! នេះជាល្បិចដែលវាធ្វើឡើងដើម្បីឲ្យគេខ្លាចវាពីចម្ងាយទេតើ ! ហើយបើទុកណាជា អាត្មាអញទទូចយកបញ្ហាដដែលនេះមកឲ្យវាដោះសារទៀតក៏គង់តែមិនបានផលអ្វីសំខាន់ដែរ ហើយការពិសោធបែបនេះក៏ទៅជាមិនបានការ ៗ ហើយក៏ទ្រង់ប្រទានរង្វាន់ជាច្រើនមានមាស-ប្រាក់សំពត់អាវជាដើម ដល់កុមារជ័យ ។ ក៏បានទទួលដោយសោមនស្សហើយក៏យកទៅជូនមាតាបិតាខ្លួនទាំងអស់ ៗ (នៅមានត)

---

# បុណ្ណកុមារ

(៧)

សត្យាទរៈរាជកុមារស្ទុះបួលមកឱបព្រះរៀមព្រមទាំងមានបន្ទូលថា

« ព្រះរៀមបង ! អូននៅចាំបានថា ព្រះមាតាតែងទ្រង់ព្រះកន្សែងសោកានឹកដល់ព្រះរៀមបងជានិច្ច ប្រសិនបើព្រះមាតាមានព្រះជន្មនៅឡើយ ម៉្លេះមិនដឹងជាទ្រង់ត្រេកអរយ៉ាងណាទេ ! »

« ព្រះមាតាទ្រង់ទិវង្គតទៅហើយឬ? » បុណ្ណមាណពសួរដោយសម្លេងញ័ររអាក់រអួល

« ទិវង្គតទៅហើយ សត្យយុត្តាសម្លាញ់អើយ ! » ព្រះរាជាទ្រង់មានព្រះបន្ទូល

ផងអណ្ដើលខ្លួនបុណ្ណមាណពផងដោយសេចក្ដីអាណិតអាសូរ «មាតារបស់កូនឯងទិវង្គត ៧ឆ្នាំហើយ តែមុនពេលផុតអាយុបន្តិចគេបានផ្ដែផ្ដាំឲ្យបិតា ស៊ើបសួររកកូនឯងឲ្យឃើញ បិតាក៏បានព្យាយាមរកណាស់ដែរ តែក៏គ្មានលេចឮដំណឹងសោះទាល់តែមកដល់ឥឡូវនេះ..»

បុណ្ណមាណពមិនអាចនឹងទប់ទល់នៅទឹកភ្នែកមិនឲ្យហូរស្រក់ធ្លាក់ចុះចាកដួងនេត្រា បានក្នុងកាលដែលបានដឹងថាម្ដាយដែលមានគុណធ្ងន់សែនធ្ងន់ក្នុងខ្លួនអនិច្ចកម្មទៅហើយនោះ ព្រោះមិនដែលបានឃើញមុខមាត់យ៉ាងណាសោះៗ លុះស្ងាងនូវការសោយសោកហើយ ព្រះរាជាក៏បរិយាយរ៉ាយរ៉ាប់ដល់រឿងដែលកើតឡើងតាំងពីដើមឲ្យបុណ្ណមាណពស្ដាប់

«មនុស្សដែលកូនឯងហៅ «តា» ហើយដែលស្លាប់ទៅហើយនោះគឺកាយទសកៈ ត្រូវជាឪពុកមារបស់កូនឯង» ព្រះរាជាទ្រង់ត្រាស់ក្នុងទីបំផុត «តែល្អើយចុះ យ៉ាងម៉េចៗ ក៏វាស្លាប់ទៅហើយ ឪពុកក៏មិនបង់កម្មចងពៀរនឹងវាតទៅទៀតដែរ» ។

បុណ្ណមាណពប្ដូរសត្យយុទ្ធាភជឧសេចប្ដឹងរបស់ព្រះបាទសត្យភជព្រះរាជានៃកល្យាណីបុរៈនគរ បានបញ្ចេញយោបល់ថ្វាយព្រះរាជាថា នឹងធានាធ្វើការទាក់ទងជាមួយនឹងកងទ័ពទេវគិរីនគរឲ្យឈប់ច្បាំងគ្នា ហើយនឹងធ្វើនគរទាំងពីរនេះឲ្យមានសម្ពន្ធមេត្រីរាប់រកគ្នានឹងគ្នាតរៀងទៅ ល្អជាជាងការដែលនាំគ្នាច្បាំងកាប់ចាក់សម្លាប់គ្នាដោយមិនសមហេតុផល ដូច្នោះព្រួញដែលមានសំបុត្របុងជាប់នៅត្រង់ចុងក៏បានហោះចេញពីបន្ទោះធ្នូនៃបុណ្ណមាណពពីក្នុងកំពែងនគរទៅកាន់បន្ទាយនៃកងទ័ពខ្មាំង

(នៅមានត)

# ប្រវត្តិក្មេងកំព្រា (ត)

គេឃើញគប់ភ្លើងព្រាតព្រោងកំពុងតែប្រទក្សិណចុះឡើងពាសពេញព្រៃ ជាសញ្ញាឲ្យដឹងថាក្រុមរបស់នាយវិន្ទា ដែលមានសំណាងនៅក្នុងទីនោះផង កំពុងតែតាមរកនាយវិន្ទានឹងកញ្ញានារី ។ ការតាមរកនេះនាំឲ្យសហការីទាំងឡាយអស់សង្ឃឹមតែរៀងខ្លួន ព្រោះពុំមានហេតុអ្វីដែលនាំឲ្យគេមានកម្លាំងក្នុងការតាមរកនេះសោះ, មានតែសំណាងមួយប៉ុណ្ណោះទេ ដែលជាអ្នកឈ្លាសវៃក្នុងការតាមរកនេះ ។ អ្នកបានពិនិត្យមើលដោយសព្វគ្រប់នូវហេតុផ្សេងៗ ក្នុងជម្រំនឹងក្រៅជម្រំទាំងពីរ; មិនយូរប៉ុន្មានក៏អាចឲ្យអ្នកពិនិត្យឃើញបានខ្លះនូវស្នាមជើងដែលជាន់លើផែនដីសើមៗ តែស្នាមជើងនោះគេមិនអាចតាមរកឲ្យបានឆ្ងាយទៅទៀតឡើយ ព្រោះមានដុំថ្មជាច្រើនដែលត្រូវអ្នកគេចខ្លួនដើរជាន់ ហើយត្រូវលប់បាត់ក្នុងពេលមានគ្រាប់ភ្លៀងធ្លាក់មកលើ ។ ការស្វែងរកនេះកាន់តែជឿនដំណើរទៅមុខខ្លះហើយ ព្រោះបេះតែមានហេតុដែលល្មមឲ្យអ្នកស្វែងរកសង្ឃឹមនឹងឡើងដំណើរទៅមុខទៀត ។ មិនយូរប៉ុន្មានទេ សំណាងបានប្រទះខ្មោចខ្លាមួយដែលត្រូវដេកស្លាប់ថ្មីៗ ។ អ្នកបានប្រមូលសហការីទាំងអស់ដើម្បីឲ្យជួយពិនិត្យចំពោះខ្មោចខ្លានេះថា តើខ្លាវាស្លាប់ដោយប្រខាំនៃសត្វផងគ្នាឬដោយមនុស្សប្រហារ ។

ការវិនិច្ឆ័យក៏បានជាក់ស្តែងឡើងដោយសហការីទាំងប៉ុន្មានធ្លាប់ដឹងស្នាដៃនៃនាយវិន្ទា ហើយស្គាល់ច្បាស់ទៅទៀតថា ខ្លានេះស្លាប់ដោយកាំបិតស្នៀតរបស់នាយវិន្ទាប្រាកដ ។ ក្រោយនេះបន្តិចអ្នកតាមទាំងប៉ុន្មានក៏ត្រូវត្រឡប់វិញ ហើយសែងទាំងខ្លាដែលស្លាប់នោះមកផង ដោយមានបង្គាប់ពីសំណាងថា «យើងទាំងអស់គ្នាបើបេះតែដើររករបៀបនេះនឹងមិនឃើញដោយដាច់ខាត ព្រោះអ្នកដែលគេចទៅនេះប្រាកដជាធ្វើ

ដំណើរទៅឆ្ងាយហើយ បើមិនជឿសូមអ្នកទាំងឡាយមើលឈាមខ្ញានេះចុះ កករឹងស្ទើរតែទាំងអស់ តែយើងមិនលះបង់ការស្វែងរកនេះទេ ដោយខ្ញុំដឹងច្បាស់តាមយោបល់ខ្ញុំថា អ្នកទាំងពីរមិនទាន់ចេញផុតពីកោះនៅឡើយ ហើយមុខជាសំណាក់នៅទីណាមួយមិនខាន ព្រោះនៅចុងក្រចកខ្ញា មានឈាមប្រឡាក់ខ្លះ នោះយើងដឹងបានថាអ្នកតយុទ្ធនឹងមានរបួសខ្លះមិនលែង ហើយអ្នកទាំងពីរមុខជាឈប់រក្សារបួសសិន ដោយការឈឺចាប់នៃពិសក្រចកខ្ញា ៗ មួយវិញទៀតបើយើងប្រឹងតាមទាំងរាត្រីដូចនេះ នឹងធ្វើឲ្យបាត់ស្នាមជើងនៅលើថ្ម ដោយការដើរជាន់នៃក្រុមពួកយើង, ដូច្នោះចាំពន្លឺព្រះអាទិត្យបញ្ចេញរស្មីច្បាស់ពេលណា ពេលនោះយើងនឹងត្រូវស្វែងរកម្តងទៀត,, ៗ

ក្នុងរឿងកំសត់មួយនេះគួរឲ្យអ្នកមានទុក្ខសម្រក់ទឹកភ្នែកយ៉ាងច្រើនហើយនឹងធ្វើឲ្យចក្ខុទាំងគូនៃអ្នកសោកសៅស្ទើរតែមានឈាមហូរលាយជាមួយផង ៗ រាងកាយអ្នកជម្ងឺនៅតែស្ដុកស្ដឹងដដែល មិនមានហេតុអ្វីគួរឲ្យអ្នកថែរក្សាជម្ងឺមានសង្ឃឹម ព្រោះអ្នកជម្ងឺនេះបាត់ស្មារតីទៅហើយដង្ហើមចេញចូលនៅស្តួចស្តើងណាស់ តែខ្លួនអ្នកជម្ងឺនៅមានធាតុក្តៅនៅឡើយ បំណែកសសៃឈាមវិញក៏ដើរយ៉ាងខ្លាំងហើយញាប់ផង បើតាមវិទ្យាសាស្ត្រគេថាអ្នកជម្ងឺមានគ្រុនខាងក្នុងខ្លាំង ៗ នារីមួយរូបដែលកំពុងតែអង្គុយរក្សាជម្ងឺនាងអស់សង្ឃឹម នាងស្ទើរតែយកកាំបិតស្នៀតរបស់នាយវិន្ទាដែលបានប្រហារខ្ញានេះមកសម្លាប់ខ្លួនឯងតែម្តង ៗ ប៉ុន្តែលោកអើយ ! ការផ្តាច់ជីវិតខ្លួនឯងមិនងាយទេព្រោះសភាពមនុស្សគ្រប់រូបគ្មាននរណាមួយស្អប់ជីវិតរបស់ខ្លួនឡើយ ៗ ដូចនេះហើយបានជាមធ្យោបាយរបស់នាងមានតែមួយប៉ុណ្ណោះគឺការអង្គុយសម្រក់ទឹកភ្នែក ៗ

(នៅមានត)

រោងពុម្ពទវិយ
នៅខាងត្បូងផ្សារអូរឫស្សីសង្កាត់លេខ៥